79|:

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាឧទ្ធរណ៍ភ្នំពេញ**

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ៖ ១០២២
ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨
**សាលដីកា**
លេខ៖ ៦៦ ក្រV«រ»
ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតតាមច្បាប់ស្ដីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ ៖ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ និងបើកសវនាការជាអសាធារណៈ នៅសាលាឧទ្ធរណ៍នាថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ ដោយមានសមាសភាពដូចតទៅ ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

**ឯកឧត្តម** [redacted] **ប្រធានក្រុមប្រឹក្សា**
**លោកស្រី** [redacted] **ចៅក្រមប្រឹក្សា**
**លោក** [redacted] **ចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**កញ្ញា** [redacted] **ព្រះរាជអាជ្ញា**

**ក្រឡាបញ្ជីសវនាការ**

**កញ្ញា** [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១០២២ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ លើ ៖

១- ជនជាប់ចោទឈ្មោះ [redacted] ស្រីណែត ហៅជា ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ អ្នកកាប់លុយ ទីកន្លែងកំណើត សង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃុំផ្ទះលេខ [redacted] ភូមិដើមច័ន្ទ សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រស់) ម្ដាយឈ្មោះ [redacted] (រស់) ប្ដីឈ្មោះ [redacted] (លែងលះ) មានកូន០២នាក់ ទោសពីមុនគ្មាន ជានីតិជន ។ (ប្ដឹងឧទ្ធរណ៍)

-ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៨៣០៩ (ង)ដយដ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧ ។

✓ ២- ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ហៅសិដ្ឋ ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរលក់ឪស មានទីកន្លែងកំណើតនៅខេត្តព្រៃវែង អាសយដ្ឋានបច្ចុប្បន្ន [redacted] សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្ដាយឈ្មោះ [redacted] (រស់) នៅលីវ ជានីតិជន។ (ប្ដឹងឧទ្ធរណ៍)

-ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៨៣០៨ (ង)ដយដ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧ ។





Scanned with CamScanner

✓ ៣-ជនជាប់ចោទឈ្មោះ [redacted]បញ្ញា ហៅឡាឬប៊ិះ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរជាងសាក់ ទីកន្លែងកំណើតផ្សារលើ ក្រុងកំពង់សោម អាសយដ្ឋានបច្ចុប្បន្នមិនពិតប្រាកដ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (ស្លាប់) នៅលីវ ទោសពីមុនគ្មាន ជាអនីតិជន។ (ប្តឹងឧទ្ធរណ៍)

-ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៨៣០៧ (ង)ជយជ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧ ។

<u>ជាប់ចោទពីបទ</u> ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចខុនដូរលេខ១២៥ (បន្ទប់លេខ៥២) ផ្លូវលេខ៨៤B សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

<u>អង្គហេតុមានដូចតទៅ ៖</u>

កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ប្រហែលវេលាម៉ោងប្រមាណ១៦ និង១០នាទី ដោយមានការដឹកនាំសម្របសម្រួលពីតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ កម្លាំងការិយាល័យប្រឆាំងជំនួញគ្រឿងញៀនខុសច្បាប់នៃមន្ទីរប្រឆាំងគ្រឿងញៀនបានចុះអនុវត្តវិធានប្រគល់ដោយមានការឃ្លាំមើល ឬញុះញង់ឲ្យលក់គ្រឿងញៀនខុសច្បាប់ និងបានបង្ក្រាបចំពេលមុខសញ្ញាកំពុងធ្វើសកម្មភាពនៅចំណុចខុនដូរលេខ១២៥(បន្ទប់៥២) ផ្លូវលេខ៨៤B សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដោយមានការឃាត់ខ្លួនជនសង្ស័យចំនួន១នាក់ ឈ្មោះ [redacted] ស្រីណែត ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិខ្មែរ និងចាប់យកវត្ថុតាង សារធាតុញៀនប្រភេទមេតំហ្វេតាមីន(ICE) ទម្ងន់៣,៦៣ក្រាម ហើយភ្លាមៗនោះ យើងបាននាំខ្លួនជនសង្ស័យនេះទៅចង្អុលបង្ហាញបន្ទប់ខុនដូរលេខ៥២ របស់មេខ្លោង និងជាម្ចាស់សារធាតុញៀនប្រភេទមេតំហ្វេតាមីន(ICE) ទម្ងន់ ៤៩៥,៥០ ក្រាម ដោយឃាត់បានជនសង្ស័យចំនួន២នាក់មានឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] បញ្ញា ភេទប្រុស អាយុ១៧ឆ្នាំ ហើយបានកសាងសំណុំរឿងបញ្ជូនជនសង្ស័យ និងវត្ថុតាងមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។ (តាមលទ្ធផលកោសលវិច័យ កម្រិតភាពសុទ្ធសរុប ៣៧៤,៣៥% នៃទម្ងន់សរុបជារបស់ឈ្មោះ [redacted] ពិសិដ្ឋ និងកម្រិតភាពសុទ្ធសរុប ២,៦៨% នៃទម្ងន់សរុបជារបស់ឈ្មោះ [redacted] ស្រីណែត )។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៥១៤ ក្រ២ «វ» ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១. ផ្តន្ទាទោស

ក. ឈ្មោះ [redacted] ស្រីណែត ហៅដា ភេទស្រី អាយុ២៧ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២៣ (ម្ភៃបី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០,០០០,០០០ (ហាសិបលាន) រៀល ។

ខ. ឈ្មោះ [redacted] ពិសិដ្ឋ ហៅសិដ្ឋ ភេទប្រុស អាយុ២៣ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២៣ (ម្ភៃបី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០,០០០,០០០ (ហាសិបលាន) រៀល ។

គ. ឈ្មោះ [redacted] បញ្ញា ហៅឡា ឬប៊ិះ ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២០ (ម្ភៃ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤០,០០០,០០០ (សែសិបលាន) រៀល ។

ពីបទ ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចខុនដូរលេខ១២៥ (បន្ទប់លេខ៥២) ផ្លូវលេខ៨៤B សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

២. រឹបអូសវត្ថុចាប់យក តាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គឺ ៖

ក. ស្រោមសំបុត្រពណ៌គគីចំនួន១សរសេរថា កញ្ចប់វត្ថុតាងគ្រឿងញៀន ប្រភេទម្សៅក្រាមពណ៌សថ្លា ទម្ងន់ ៤៩៥,៥០ ក្រាម (បួនរយកៅសិបប្រាំកណ្តាក់សញ្ញាហាសិបក្រាម) ដោយជនសង្ស័យឈ្មោះ [redacted] ពិសិដ្ឋ ផ្តិតមេដៃទទួលស្គាល់ និងហត្ថលេខាមន្រ្តីនគរបាលយុត្តិធម៌រួមជាមួយផង និង

ខ. ស្រោមសំបុត្រគគីចំនួន១ សរសេរថា កញ្ចប់វត្ថុតាងគ្រឿងញៀន ប្រភេទម្សៅក្រាមពណ៌សថ្លា ទម្ងន់ ៣,៦៣ ក្រាម (បីកណ្តក់សញ្ញាហុកសិបបីក្រាម) ដោយជនសង្ស័យឈ្មោះ [redacted] ស្រីណែត បានផ្តិតមេដៃទទួលស្គាល់ និងហត្ថលេខាមន្រ្តីនគរបាលយុត្តិធម៌រួមជាមួយផង និង

គ. ទូរស័ព្ទដៃចំនួន២គ្រឿងមាន NOKIA ពណ៌ក្រហមលាយខ្មៅចំនួន១ និងម៉ាក SAMSUNG ពណ៌សចំនួន១ចាស់ (មិនដំណើរការ) និងជញ្ជីងថ្លឹងចំនួន២ ។

-សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស្រីណែត ,ឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] បញ្ញា , មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងប្រកាសជាអសាធារណៈនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨។

-បើកសិទ្ធិប្តឹងឧទ្ធរណ៍ ក្នុងរយៈពេលដែលច្បាប់កំណត់។

-បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៥៧២ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ស្រីណែត , លេខ ៥០៩ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ , លេខ ៥១៤ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ប្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៥១៤ ក្រ២ «វ» ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូលនៃសាលក្រម។

-បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

-បានឃើញ សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩។

<u>នាពេលសវនាការ</u>

១-ជនជាប់ចោទឈ្មោះ [redacted] ស្រីណែត (វត្តមាន)

២-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ហៅសិដ្ឋ (វត្តមាន)

៣-ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ហៅឡាឬបិះ (វត្តមាន)

-មេធាវី [redacted] ហុង ការពារសិទ្ធិឲ្យជនជាប់ចោទ (វត្តមាន)

-មេធាវី [redacted] ម៉ារ៉ឺឌី ការពារសិទ្ធិឲ្យជនជាប់ចោទ (វត្តមាន)

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

-ប្រធានក្រុមប្រឹក្សាពីប្រាប់សិទ្ធិដល់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] ស្រីណែត បានឆ្លើយថា ៖ មូលហេតុដែលខ្លួនប្តឹងឧទ្ធរណ៍ គឺដោយសារសាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោសមកលើខ្លួនមានលក្ខណៈធ្ងន់ធ្ងរពេក។ កាលពីថ្ងៃកើតហេតុ ខ្លួនបានទៅទិញគ្រឿងញៀននៅចំណុចខុនដូរលេខ១២៥ ជាន់ទី៥ បន្ទប់លេខ៥៥២ ហើយបានទិញក្នុងតម្លៃ១០០ (មួយរយ)ដុល្លាអាមេរិក ដោយអ្នកលក់បានហុចគ្រឿងញៀននោះអោយតាមប្រឡោះទ្វារ ហេតុនេះខ្លួនមិនស្គាល់



Scanned with CamScanner

អត្តសញ្ញាណអ្នកលក់នោះទេ។ ក្រោយពីទិញបានហើយ ខ្លួនក៏បានចុះមកក្រោមវិញ ស្រាប់តែត្រូវសមត្ថកិច្ចចាប់ខ្លួនបានតែម្តង រួចហើយសមត្ថកិច្ចបាននាំខ្លួនទៅចំណុចទិញលក់វិញគឺបន្ទប់លេខ៥២ នៅពេលនោះខ្លួនបានឃើញឈ្មោះ[redacted]បញ្ញា និង[redacted]ពិសិដ្ឋ រួមជាមួយនឹងថ្នាំញៀនជាច្រើន តែខ្លួនក៏មិនដឹងថាជារបស់អ្នកណាដែរ។ នៅក្រោយពេលឃាត់ខ្លួន សមត្ថកិច្ចបានធ្វើការដកហូតជញ្ជីងថ្លឹងគ្រឿងញៀនមួយទៀតមិនមែនជារបស់ខ្លួនទេ តែសមត្ថកិច្ចបានបង្ខំឲ្យខ្លួនទទួលស្គាល់។

-ជនជាប់ចោទឈ្មោះ[redacted]ពិសិដ្ឋ បានឆ្លើយថា ៖ កន្លងមកខ្លួនបានស្នាក់នៅបន្ទប់លេខ៥២ ជាន់ទី៥ នៃខុនដូរលេខ១២៥នេះបានរយៈពេលប្រហែល៣ខែហើយ ដោយស្នាក់នៅជាមួយឈ្មោះ ស្រីណែត និងឈ្មោះ តី ចំណែកឯឈ្មោះ[redacted]បញ្ញា គឺបានមកលេងដើម្បីប្រើប្រាស់គ្រឿងញៀនម្តងម្កាលទេ។ នៅថ្ងៃកើតហេតុ ឈ្មោះ ស្រីណែត បានមកទិញគ្រឿងញៀន ហើយឈ្មោះ តី ជាអ្នកហុចអោយ ដែលពេលនោះខ្លួនកំពុងមុជទឹក។ មុនពេលសមត្ថកិច្ចចាប់ខ្លួនបាន ខ្លួនបានបបួលឈ្មោះ [redacted] បញ្ញា ជិះទៅយកថង់ខោអាវដែលមានខ្ចប់គ្រឿងញៀននៅម្តុំចំណុចផ្សារដើមថ្កូវ បានមកពីឈ្មោះ ឡុង ហៅ ៣វ យកមកទុកនៅនឹងបន្ទប់លេខ៥២ ស្រាប់តែប្រហែលរសៀលម៉ោង១ក៏មានសមត្ថកិច្ចចុះបង្ក្រាបនិងឃាត់ខ្លួនបានតែម្តងទៅ។ ក្នុងថង់ខោអាវនោះ មានគ្រឿងញៀនប្រហែល ៤៩៥,៨០ ក្រាម។

-ជនជាប់ចោទឈ្មោះ[redacted] បញ្ញា ហៅឡាបឹះ បានឆ្លើយថា ៖ ខ្លួនពិតជាបានប្រើប្រាស់គ្រឿងញៀនមែន ហើយគ្រឿងញៀនដែលបានប្រើប្រាស់នោះគឺបានមកពីឈ្មោះ តី ចំណែកឯថង់ខោអាវដែលមានគ្រឿងញៀននៅខាងក្នុងនោះវិញ បានមកពីឈ្មោះ[redacted] ពិសិដ្ឋ ជាអ្នកនាំខ្លួនជិះទៅយកពីផ្សារដើមថ្កូវមក។ នៅថ្ងៃកើតហេតុ ពេលដែលសមត្ថកិច្ចបានចុះបង្ក្រាបនោះ ខ្លួនមិនបានបោះថង់ខោអាវដែលមានខ្ចប់គ្រឿងញៀននោះចុះទៅក្រោមទេ តែដោយសារវាអិលធ្លាក់ទៅក្រោម។

តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន

-តំណាងមហាអយ្យការយល់ឃើញថា ក្រោយពីបានធ្វើការពិភាក្សាដេញដោល និងបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ស្រីណែត , ឈ្មោះ[redacted]ពិសិដ្ឋ និងឈ្មោះ[redacted]បញ្ញា តំណាងមហាអយ្យការសម្គាល់ឃើញថា ជនជាប់ចោទទាំងបីគឺពិតជាបានប្រព្រឹត្តនូវបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀននៅចំណុចខុនដូរលេខ១២៥ (បន្ទប់លេខ៥២) ផ្លូវលេខ៤៤B សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៧ ក្នុងនោះគ្រឿងញៀនដែលសមត្ថកិច្ចបានចាប់យកមានទម្ងន់ ៤៩៥,៥០ ក្រាម ហើយចំណែកឯកម្រិតភាពសុទ្ធមានចំនួន ៧៥,៥៥% នៃទម្ងន់សរុប។ តំណាងមហាអយ្យការយល់ឃើញថា សាលក្រមព្រហ្មទណ្ឌលេខ ៥១៤ ក្រ២ «វ» ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញបានសម្រេចសេចក្តីត្រឹមត្រូវហើយ ហេតុនេះស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះនៃសភាព្រហ្មទណ្ឌតម្កល់ទុកជាបានការដដែល។

មេធាវីការពារសិទ្ធិជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន



Scanned with CamScanner

-មេធាវី [redacted]ហុង ៖ ខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ស្រីណែត។ ក្រោយពីបានស្តាប់ការពិភាក្សាដេញដោល ឃើញថាឈ្មោះ [redacted] ស្រីណែត ពិតជាបានបំពេញគ្រប់ធាតុផ្សំបទល្មើសព្រហ្មទណ្ឌពិតមែន គឺធាតុផ្សំនីត្យានុកូល ធាតុផ្សំសត្យានុម័ត និងជាធាតុផ្សំអត្តនោម័ត ដូចមានចែងនៅក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។ យោងតាមកំណត់ហេតុនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលព្រះរាជអាជ្ញា និងដំណាក់កាលចៅក្រមស៊ើបសួរ កូនក្តីខ្លួនបានឆ្លើយទទួលស្គាល់ថា «គាត់គឺពិតជាបានប្រើប្រាស់គ្រឿងញៀនពិតមែនដោយសារតែខូចចិត្ត និងមានការទាស់ទែងជាមួយប្តីហូតឈានដល់ការលែងលះគ្នាថែមទៀតផង» គ្រឿងញៀនដែលទិញយកមកប្រើប្រាស់នោះគឺកូនក្តីខ្លួនទិញមកពីឈ្មោះ [redacted] ពិសិដ្ឋ ។ ក្រោយមកស្រាប់តែមានមនុស្សប្រុសម្នាក់ទាក់ទងមកកូនក្តីខ្លួនថា « ចង់ទិញថ្នាំ» ដោយសារតែចង់បានប្រាក់ចំណេញបន្តិចបន្តួច កូនក្តីខ្លួនក៏បានទៅយកថ្នាំពីឈ្មោះ[redacted] ពិសិដ្ឋ មួយជីក្នុងតម្លៃ ១០០ (មួយរយ)ដុល្លារអាមេរិក ដើម្បីយកមកលក់បន្តហើយជាក់ស្តែងកូនក្តីខ្លួនទើបតែប្រព្រឹត្តជាលើកទី១ប៉ុណ្ណោះ។ ផ្ទុយទៅវិញការឆ្លើយបំភ្លឺនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដែលបានបញ្ជាក់ថា «វត្ថុតាងដែលចាប់បានមានជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀន » នោះមិនមែនជាការពិតទេ ព្រោះជញ្ជីងនោះមិនមែនជារបស់កូនក្តីខ្លួនឡើយ ដោយសារតែមន្ត្រីនគរបាលយុត្តិធម៌ បានបង្ខំអោយកូនក្តីខ្លួនឆ្លើយសារភាពទទួលស្គាល់កំហុសទាំងអស់ ហើយពេលនោះកាន់តែមានភាពភ័យខ្លាចខ្លាំងពេកទើបកូនក្តីខ្លួនឆ្លើយទទួលស្គាល់តែម្តងទៅប៉ុន្តែជាក់ស្តែងជញ្ជីងនោះជារបស់ [redacted] ពិសិដ្ឋ ទេ។ ចំពោះការសម្រេចសេចក្តីរបស់សាលាដំបូងរាជធានីភ្នំពេញបានផ្តន្ទាទោសដាក់ពន្ធនាគារកូនក្តីខ្លួនរហូតដល់ទៅ ២៣(ម្ភៃបី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០,០០០,០០០ (ហាសិបលាន) រៀល មានលក្ខណៈធ្ងន់ធ្ងរណាស់ដែលជាហេតុនាំឲ្យកូនក្តីខ្លួនមិនអាចទទួលយកបានឡើយព្រោះបរិមាណជាតុសុទ្ធសុទ្ធនៃសារធាតុញៀន ដែលកូនក្តីខ្លួនបានជួញដូរនោះមិនច្រើនទេ គឺមានទម្ងន់ត្រឹមតែ ២,៦៨ ភាគរយ តែប៉ុណ្ណោះ។ មិនដូចជាទម្ងន់ដែលច្បាប់បានកំណត់នៅក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នោះឡើយ។ សូមគោរពស្នើសុំអោយ ឯកឧត្តមប្រធាន មេត្តាពិនិត្យ ពិចារណាលើការផ្តល់នូវស្ថានសម្រាលទោសអោយកូនក្តីខ្លួន ដើម្បីឲ្យមានឱកាសកែប្រែខ្លួនធ្វើជាមាតាល្អ និងប្រជាពលរដ្ឋល្អនៅក្នុងសង្គមឡើងវិញ។

-មេធាវី [redacted]ម៉ារ៉ីឌី ៖ ខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ[redacted]ពិសិដ្ឋ និងឈ្មោះ [redacted] បញ្ញា សូមធ្វើសេចក្តីថ្លែងការណ៍ដូចតទៅ៖ ក្រោយពីបានស្តាប់ចម្លើយរបស់ឈ្មោះ [redacted]ពិសិដ្ឋ និងឈ្មោះ [redacted] បញ្ញា ឃើញថាអង្គហេតុខាងលើនេះជាអង្គហេតុប្រើប្រាស់គ្រឿងញៀនទេ ព្រោះកូនក្តីខ្លួនពុំបានដឹងអំពីការលក់គ្រឿងញៀន ជាក់ស្តែងគឺឈ្មោះ ៣វ និងឈ្មោះ តី ដែលជាអ្នកនាំកូនក្តីខ្លួនទៅប្រព្រឹត្តនិងប្រើប្រាស់គ្រឿងញៀនហើយចំពោះថង់ខោអាវដែលមានខ្ចប់គ្រឿងញៀននោះវិញ កូនក្តីក៏មិនបានដឹងមុន ឬមិនបានឆែកមើលថាតើនៅក្នុងថង់នោះមានអ្វី។ ម្យ៉ាងវិញទៀត បើមើលទៅលើចម្លើយរបស់កូនក្តីខ្លួននៅដំណាក់កាលចៅក្រមស៊ើបសួរ គឺកូនក្តីខ្លួនបានឆ្លើយបដិសេធចម្លើយនៅដំណាក់កាលមុនៗអស់ហើយ ហេតុនេះសាលាដំបូងយកតែចំណុចក្នុង



Scanned with CamScanner

កំណត់ហេតុរបស់សមត្ថកិច្ចមកធ្វើការចោទប្រកាន់។ សំណូមពរឲ្យក្រុមប្រឹក្សាមេត្តាពិចារណាធ្វើការផ្លាស់ប្តូរបទចោទមកជាបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនវិញ។

## សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] ស្រីណែត ៖ សូមតុលាការមេត្តាបន្ធូបន្ថយទោសមកលើរូបខ្លួនផង ដើម្បីឲ្យខ្លួនអាចត្រឡប់ទៅរស់នៅជាមួយកូនតូចៗពីនាក់វិញផង។

-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ៖ សូមតុលាការមេត្តាបន្ធូបន្ថយទោសមកលើរូបខ្លួន ដើម្បីឲ្យខ្លួនបានទៅរស់នៅជួបជុំគ្រួសារវិញ។

-ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ៖ សូមឲ្យតុលាការជួយរកយុត្តិធម៌ឲ្យខ្លួនផង និងសូមបន្ធូបន្ថយទោសដើម្បីឲ្យខ្លួនបានត្រឡប់ទៅរស់នៅជាមួយគ្រួសារវិញ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ។

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ។

-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ។

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាឧទ្ធរណ៍យល់ឃើញថា

១/.បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ,បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៨ ជនជាប់ចោទឈ្មោះ [redacted] បញ្ញា និងបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ស្រីណែត ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥១៤ «វ» ក្រ២ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងតាមមាត្រា ៤៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៨២ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន។

២/.ការដែលជនជាប់ចោទឈ្មោះ [redacted] ស្រីណែត បានឆ្លើយថា ៖ ខ្លួនបានធ្វើសកម្មភាពជួញដូរគ្រឿងញៀនប្រាកដមែន ប៉ុន្តែគ្រឿងញៀនដែលជារបស់ខ្លួនហើយត្រូវបានសមត្ថកិច្ចចាប់បាន ឃាត់ទុកដាក់ស្លែងនោះគឺមានចំនួន ៣,៦៣ ក្រាម គឺខ្លួនបានទិញពីឈ្មោះ [redacted] ពិសិដ្ឋ ក្នុងតម្លៃ ១០០ (មួយរយ) ដុល្លាអាមេរិក និងលក់វិញបានចំណេញប្រាក់បន្តិចបន្តួច។ ចំណែកគ្រឿងញៀនកញ្ចប់ធំ ដែលមានទម្ងន់សរុប ៤៩៥,៥០ ក្រាម នោះ គឺជារបស់ឈ្មោះ [redacted] ពិសិដ្ឋ ទេ ហើយខ្លួនមិនបានដឹងពីគ្រឿងញៀនកញ្ចប់ធំនោះ បានមកពីណាទេ នោះឃើញថា ពុំមានលក្ខណៈត្រឹមត្រូវឡើយ ព្រោះនៅពេលសវនាការនេះជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយថា កន្លងមក



Scanned with CamScanner

ខ្លួនបានស្នាក់នៅបន្ទប់លេខ៥២ ជាន់ទី៥ នៃខុនដូរលេខ១២៥នេះបានរយៈពេលប្រហែល៣ខែហើយដោយស្នាក់នៅជាមួយឈ្មោះ ស្រីណែត និងឈ្មោះ តី ចំណែកឯឈ្មោះ [redacted] បញ្ញា គឺបានមកលេងដើម្បីប្រើប្រាស់គ្រឿងញៀនម្តងម្កាលទេ ។

ចំណុចនេះ បញ្ជាក់ឲ្យឃើញថាជនជាប់ចោទឈ្មោះ [redacted] ស្រីណែត គឺជាសហចារីដែលបានប្រព្រឹត្តបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រភេទមេតំហ្វេតាមីនមានទម្ងន់ ៤៩៩,៥០ ក្រាម ដែលមានបរិមាណជាតុសុទ្ធទម្ងន់ ៤៩៩,៥០ក្រាម គុណ៧៥,៥៥% ស្មើនឹង ៣៧៤,៣៥ក្រាម ប្រាកដមែន ។

៣/.សំអាងហេតុរបស់សាលាដំបូង មានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ ហើយក្រុមប្រឹក្សាជំនុំជម្រះ ឯកភាពនឹងសំអាងហេតុទាំងនេះ ដោយមិនចាំបាច់លើកយកសំអាងហេតុដដែលមកបញ្ជាក់ជាថ្មីទៀតទេ។

៤/.តំណាងមហាអយ្យការបានធ្វើការសន្និដ្ឋានថា ៖ ក្រោយពីបានធ្វើការពិភាក្សាដេញដោល និងស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីណែត , ឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] បញ្ញា តំណាងមហាអយ្យការកត់សម្គាល់ឃើញថា ជនជាប់ចោទទាំងបីពិតជាបានប្រព្រឹត្តនូវបទល្មើស ជួញដូរដោយខុសច្បាប់នូវសារជាតុញៀន នៅចំណុចខុនដូរលេខ១២៥ (បន្ទប់លេខ៥២) ផ្លូវលេខ៤៤B សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ហើយក្នុងនោះគ្រឿងញៀនដែលសមត្ថកិច្ចបានចាប់យកមានទម្ងន់ ៤៩៩,៥០ ក្រាម ចំណែកឯកម្រិតភាពសុទ្ធមានចំនួន ៧៥,៥៥% នៃទម្ងន់សរុប។ តំណាងមហាអយ្យការយល់ឃើញថា សាលក្រមព្រហ្មទណ្ឌលេខ ៥១៤ ក្រ២ «វ» ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញបានសម្រេចសេចក្តីត្រឹមត្រូវហើយ ហេតុនេះស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះនៃសភាព្រហ្មទណ្ឌតម្កល់ទុកជាបានការដដែល។

ក្រុមប្រឹក្សាជំនុំជម្រះ យល់ឃើញថាការសន្និដ្ឋាននេះមានលក្ខណៈត្រឹមត្រូវ គប្បីពិចារណានិងសម្រេច។

៥/.ការដែលមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ស្រីណែត ក៏ដូចជាជនជាប់ចោទ ឈ្មោះ [redacted] ស្រីណែត និងឈ្មោះ [redacted] ពិសិដ្ឋ សំណូមពរឲ្យក្រុមប្រឹក្សាជំនុំជម្រះជួយបន្ធូរបន្ថយទោស នោះឃើញថា ពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់ឡើយ ព្រោះការប្រកាសទោសរបស់សាលាដំបូងលើជនជាប់ចោទ ឃើញថា ស្ថិតនៅក្នុងកម្រិតអប្បបរិមាហើយ បើប្រៀបធៀបនឹងគ្រឿងញៀនប្រភេទមេតំហ្វេតាមីនមានទម្ងន់ ៣៧៤,៣៥ ក្រាម ដែលត្រូវផ្តន្ទាទោស ពី២០ឆ្នាំទៅ៣០ឆ្នាំ ឬអស់មួយជីវិត ។

៦/.ការដែលមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] បញ្ញា សំណូមពរឲ្យក្រុមប្រឹក្សាជំនុំជម្រះ ធ្វើការផ្លាស់ប្តូរបទចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មកបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន វិញ នោះឃើញថា ពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់ឡើយ ព្រោះគ្រឿងញៀននោះត្រូវបានសមត្ថកិច្ចចាប់បានពីជនជាប់ចោទក្នុងបទល្មើសជាក់ស្តែង ។

៧/.ការដែលជនជាប់ចោទឈ្មោះ [redacted] បញ្ញា បានសំណូមពរស្នើសុំបន្ធូរបន្ថយទោស នោះឃើញថា មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ព្រោះជនជាប់ចោទឈ្មោះ [redacted] បញ្ញា អាយុ១៧ឆ្នាំ ជាអនីតិជន នៅពេលប្រព្រឹត្តបទ



Scanned with CamScanner

79/1

ល្មើស ។ ហេតុនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះ ធ្វើការបន្ធូរបន្ថយទោស ដោយអនុវត្តតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

៨/.សាលក្រមព្រហ្មទណ្ឌលេខ ៥១៤ ក្រ២ «វ» ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការ លើកលែងតែចំណុចទី១ "គ" គប្បីកែប្រែតាមសំអាងហេតុខាងលើ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១/.ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ស្រីណែត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២/.ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

៣/.ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ហៅ ឡា រីបិះ ទុកជាត្រឹមត្រូវតាមច្បាប់។

៤/.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥១៤ ក្រ២ «វ» ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងតែចំណុចទី១, គ ដែលសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] បញ្ញា ហៅ ឡា រីបិះ អាយុ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ២០ (ម្ភៃ) ឆ្នាំ ត្រូវកែប្រែមកជាដាក់ពន្ធនាគារកំណត់រយៈពេល ១៥ (ដប់ប្រាំ)ឆ្នាំ វិញ ។

-ចំណុចផ្សេង ពីនេះរក្សាទុកនៅដដែល។

៥/.បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់។

-សាលដីកានេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស្រីណែត , ឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] បញ្ញា និងប្រកាសជាអសាធារណៈនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២។

-ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted]



Scanned with CamScanner